ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

និយ័តករសន្តិសុខសង្គម

SOCIAL PROTECTION IN CAMBODIA

ថ្ងៃព្រហស្បតិ៍ ០៤ កើត ខែ ស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី១២ ខែសីហា ឆ្នាំ២០២១

## សេចក្តីជូនដំណឹង

## ស្តីពីការដាក់ឱ្យប្រើប្រាស់និមិត្តសញ្ញា (Logo) និងត្រា របស់និយ័តករសន្តិសុខសង្គម

**និយ័តករសន្តិសុខសង្គម** មានកិត្តិយសសូមជម្រាបជូនសាធារណជនឱ្យបានជ្រាបថា៖ យោងតាមព្រះរាជក្រមលេខ នស/រកម/០១២១/០០៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ, **អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម** ត្រូវបំពេញតួនាទីបន្ថែមជា **និយ័តករសន្តិសុខសង្គម**។ ទន្ទឹមនេះ **អគ្គលេខាធិការក្រុមប្រឹក្សាជាតិគាំពារសង្គម** ត្រូវបំពេញតួនាទី និងភារកិច្ចបន្ថែមជាអគ្គនាយកនៃនិយ័តករសន្តិសុខសង្គម ផងដែរ។

អនុក្រឹត្យលេខ១១៣អនក្រ/បក ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ បានកំណត់ឱ្យ **និយ័តករសន្តិសុខសង្គម** ហៅកាត់ថា **ន.ស.ស.** មាននិមិត្តសញ្ញា (Logo) និងត្រា របស់ខ្លួន ដើម្បីប្រើប្រាស់ជាផ្លូវការដែលមានគំរូដូចខាងក្រោម៖

គំរូនិមិត្តសញ្ញា (Logo) | គំរូត្រា

អាស្រ័យហេតុនេះ សូមសាធារណជន ជ្រាបជាព័ត៌មាន។

**និយ័តករសន្តិសុខសង្គម**

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, Cambodia
ទូរស័ព្ទលេខ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666